Cooperation Committee for Cambodia · Comité de Coopération Pour le Cambodge · Australian Aid · PONLOK CHOMNES · The Asia Foundation · Co-funded by the European Union

# សិក្ខាសាលាផ្សព្វផ្សាយ

## ស្តីពី

## «ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ»

ថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០២៥ ម៉ោង ៨:០០ ព្រឹក ដល់ ១២:០០ ថ្ងៃត្រង់

ទីកន្លែង៖ **ភោជនីយដ្ឋានទន្លេបាសាក់២ (ជិតស្ពានអាកាសក្បាលថ្នល់)**, រាជធានីភ្នំពេញ

### ១.បរិបទ

ច្បាប់ស្តីពីគណនេយ្យ និងសវនកម្មត្រូវបានអនុម័ត និងប្រកាសឱ្យប្រើប្រាស់នៅព្រះរាជាណាចក្រកម្ពុជានៅក្នុងឆ្នាំ២០១៦។ ច្បាប់នេះបង្កើតឡើងក្នុងគោលបំណងគ្រប់គ្រងវិស័យគណនេយ្យ និងសវនកម្មប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពជឿទុកចិត្តបាន។ ដែលមានវិសាលភាពអនុវត្តចំពោះស្ថាប័នសាធារណៈ សហគ្រាសអង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ និងសវនករ ប៉ុន្តែមិនអនុវត្តចំពោះធនាគារកណ្តាល និងចំពោះតួនាទី និងភារកិច្ចដែលជាសមត្ថកិច្ចរបស់អាជ្ញាធរសវនកម្មជាតិនោះទេ។

ច្បាប់នេះដាក់បញ្ចូលនូវកាតព្វកិច្ចមួយចំនួនដែលកំណត់ឱ្យអង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវអនុវត្តដែលក្នុងនោះមានដូចជា កាតព្វកិច្ចរក្សាកំណត់ត្រាហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ រៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ និងរៀបចំបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុទៅកាន់និយ័តករគណនេយ្យ និងសវនកម្ម ដោយអនុវត្តតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា (CIFRS)។ ក្នុងនោះស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូច និងមធ្យម (IFRS-SMEs) និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ (CFRS for NFPEs) យោងប្រកាសលេខ៣៣៥ សហវប្រក ចុះថ្ងៃទី២៧ មីនា ឆ្នាំ២០១៨ ស្តីពីការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ (CFRS សម្រាប់ NFPEs) ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

នៅឆ្នាំដើមឆ្នាំ២០២៥នេះ ថ្នាលឌីជីថលដែលទាក់ទងនឹងការរាយការណ៍ហិរញ្ញវត្ថុបានបង្កើតឡើងរួមទាំងការដាក់ឱ្យប្រើប្រាស់ ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថលផងដែរ។ គំនិតផ្តួចផ្តើមនេះស្របតាមគោលដៅក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥ របស់រដ្ឋាភិបាល ។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព GPP 23/02/2023 22/02/2028 Symbol of Trust

ស្របពេលដែលប្រទេសកម្ពុជាកំពុងមានវឌ្ឍនភាពក្នុងការធ្វើឱ្យប្រព័ន្ធរាយការណ៍ហិរញ្ញវត្ថុ និងពន្ធដាររបស់ខ្លួន ថ្នាលឌីជីថលដែលទាក់ទងនឹងការរាយការណ៍ហិរញ្ញវត្ថុត្រូវបានគេរំពឹងថានឹងត្រូវបានអនុវត្តយ៉ាងពេញលេញនៅឆ្នាំ២០២៥នេះ សម្រាប់ទាំងវិស័យសាធារណៈ និងឯកជន រួមទាំង អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដើម្បីជួយសម្រួលដល់ការបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុទៅកាន់និយ័តករគណនេយ្យ និងសវនកម្ម។

ដូច្នេះវាមានសារៈសំខាន់ណាស់សម្រាប់ អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដើម្បីដឹងអំពីការអនុវត្តថ្នាលឌីជីថលនេះ រួមទាំងអត្ថប្រយោជន៍ បញ្ហាប្រឈម និងលក្ខខណ្ឌផ្សេងៗនៃថ្នាលឌីជីថល ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគាត់អាចត្រៀមខ្លួនក្នុងការអនុលោមតាមនិន្នាការឌីជីថលនាពេលខាងមុខនេះ។

ដើម្បីឆ្លើយតបចំពោះតម្រូវការផ្នែកចំណេះដឹង ព័ត៌មាន និងការអនុវត្ត ដូចដែលបានរៀបរាប់ខាងលើ អង្គការ គ.ស.ក នឹងរៀបចំសិក្ខាសាលាផ្សព្វផ្សាយមួយនៅរាជធានីភ្នំពេញ។

## ២.គោលបំណង ៖

សិក្ខាសាលាផ្សព្វផ្សាយស្តីពី «**ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ**» ត្រូវបានរៀបចំឡើងក្នុងគោលបំណងសំខាន់ៗដូចខាងក្រោមនេះ៖

- ដើម្បីផ្សព្វផ្សាយ ចែករំលែកព័ត៌មាន អំពី**ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល** និងការអនុលោមតាមរបាយការណ៍ហិរញ្ញវត្ថុដល់អង្គភាពមិនរកប្រាក់ចំណេញ (NFPEs) ។
- ដើម្បីផ្តល់ទិដ្ឋភាពទូទៅ ស្តីពីការរៀបចំរបាយការណ៍ ចំណុចសំខាន់ៗ និងការកំណត់ពេលវេលាសម្រាប់ការអនុវត្តថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថលសម្រាប់NFPEs។
- ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងចំណោម NFPEs អំពីអត្ថប្រយោជន៍ និងបញ្ហាប្រឈមដែលអាចកើតមានឡើងក្នុងពេលអនុវត្ត និងក៏ដូចជាលើកទឹកចិត្តឱ្យមានការពង្រឹងសមត្ថភាពឱ្យបានមុនការអនុវត្តថ្នាលឌីជីថលនេះផងដែរ។

## ៣. វាគ្មិន

- តំណាងមកពីនិយ័តករគណនេយ្យ និងសវនកម្ម
- ក្រុមហ៊ុនសវនកម្មដែលមានជំនាញដែលមានបទពិសោធន៍ដែលមានជំនាញលើស្តង់ដាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គការមិនរកប្រាក់ចំណេញ។

## ៤. អ្នកចូលរួម

សិក្ខាសាលានេះរំពឹងនឹងមានអ្នកចូលរួមប្រមាណ **១៥០-២០០** នាក់អញ្ជើញមកពីជាតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសជាសមាជិកនៃអង្គការ គ.ស.ក បណ្តាញអង្គការសង្គមស៊ីវិលថ្នាក់ខេត្ត អង្គការដៃគូ និងភាគីពាក់ព័ន្ធដទៃផ្សេងទៀត ដែលជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុ មន្ត្រីហិរញ្ញវត្ថុ គណនេយ្យក និងអ្នកជំនាញទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានលើកទឹកចិត្ត និងអញ្ជើញឱ្យចូលរួមក្នុងសិក្ខាសាលានេះ។

## ៥. របៀបវារៈនៃកម្មវិធី

| ពេលវេលា | សកម្មភាព | អ្នកសម្របសម្រួល |
|---|---|---|
| ៨:០០-៨:៣០ | ចុះឈ្មោះអ្នកចូលរួម | ក្រុមការងារអង្គការ គ.ស.ក |
| ៨:៣០-៨:៤០ | ▪ ប្រកាសហេតុ និងគោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា<br>▪ ការណែនាំនៃកម្មវិធី និងគោលបំណងសិក្ខាសាលា | **អ្នកកាន់កម្មវិធី៖**<br>លោកស្រី **ប្រាក់ កែវឥន្ទ្រា**,<br>អ្នកឯកទេស ផ្នែកគោលនយោបាយ ច្បាប់ និងតស៊ូមតិនៃអង្គការ គ.ស.ក |
| ៨:៤០-៨:៥០ | មតិស្វាគមន៍ | លោកស្រី **ស៊ិន ពុទ្ធារី**<br>នាយិកាប្រតិបត្តិនៃអង្គការ គ.ស.ក |
| ៨:៥០-៩:១០ | សុន្ទរកថាបើកសិក្ខាសាលា | ឯកឧត្តម **ម៉ី ថារិន**<br>អគ្គនាយកនៃនិយ័តករគណនេយ្យ និងសវនកម្ម |
| ៩:១០-៩:៣០ | **ថតរូបអនុស្សាវរីយ៍ និង សម្រាកអាហារសម្រន់** | **អ្នកចូលរួមទាំងអស់គ្នា** |
| ៩:៣០-១០:១៥<br>**(៤៥នាទី)** | **បទបង្ហាញ ៖ កាតព្វកិច្ចគណនេយ្យ និងសវនកម្មសម្រាប់ NFPEs**<br>▪ ការធ្វើបច្ចុប្បន្នភាពអំពីច្បាប់និងបទប្បញ្ញត្តិស្តីពីគណនេយ្យ និងសវនកម្មសម្រាប់សម្រាប់អង្គភាពមិនរកប្រាក់ចំណេញ | លោកស្រី **តាំង ឈីវហុង**, ប្រធានការិយាល័យនីតិកម្ម និងដោះស្រាយវិវាទនៃនិយ័តករគណនេយ្យ និងសវនកម្ម |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព GPP 23/02/2023 22/02/2028 Symbol of Trust

| | | |
|---|---|---|
| ១០:១៥-១១:៣០ **(៧៥នាទី)** | **បទបង្ហាញ៖ ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល**<br>▪ ផ្តល់ទិដ្ឋភាពទូទៅ និងមុខងារសំខាន់ៗនៃថ្នាលឌីជីថល<br>▪ តម្រូវការរាយការណ៍ដែលរំពឹងទុក<br>▪ កាលបរិច្ឆេទនៃការអនុវត្ត<br>▪ ចំណុចសំខាន់ដែលពាក់ព័ន្ធអង្គភាពមិនរកប្រាក់ចំណេញ (NFPEs) | លោក **យាន ផល្លា**,ប្រធានការិយាល័យអនុលោមភាពទី៣ នៃនិយ័តករគណនេយ្យ និងសវនកម្ម |
| ១១:៣០-១២:០០ (៣០នាទី) | **វេទិកាសំណួរចម្លើយ៖ ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល** | **វាគ្មិន៖**<br>១.លោក **ស៊ឹម ចាន់គីរីរ័ត្ន** , ទីប្រឹក្សា<br>២.លោកស្រី **តាំង ឈីវហុង**, ប្រធានការិយាល័យនីតិកម្ម និងដោះស្រាយវិវាទ<br>៣.លោក **ជីវ ហ៊ី**, ប្រធានការិយាល័យព័ត៌មានវិទ្យា<br>៤.លោក **យាន ផល្លា**,ប្រធានការិយាល័យអនុលោមភាពទី៣<br>៥.លោក **ខ រ័ត្ននា**, អនុប្រធានការិយាល័យព័ត៌មានវិទ្យា<br>**អ្នកសម្របសម្រួល:**<br>លោក **អ៊ូ សារិន**, ប្រធានផ្នែកប្រតិបត្តិការនៃអង្គការ គ.ស.ក |
| ១២:០០-១:៣០ | **សម្រាកអាហារថ្ងៃត្រង់** | **អ្នកចូលរួមទាំងអស់គ្នា** |

**សម្គាល់៖ សិក្ខាសាលានេះនឹងរៀបចំឡើងជាភាសាខ្មែរ** ក្រុមការងារសូមរក្សាសិទ្ធិកែប្រែកម្មវិធីនេះក្នុងករណីចាំបាច់។

រូបភាព និងមតិយោបល់សំខាន់ៗនានានឹងត្រូវបាន ដកស្រង់ និងចែករំលែកជាសាធារណៈតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងគេហទំព័ររបស់ក្រុមការងារអ្នករៀបចំកម្មវិធី។ http://www.ccc-cambodia.org/en/resources/event-archives www.facebook.com/CCCsince1990 www.youtube.com/CCCambodia



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia